ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ៦ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន៖

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I. ទីស្តីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

៩-២-១៩៩៥ -អនុក្រឹត្យលេខ ១៥ អនក្រ ស្តីពីការតែងតាំងមន្ត្រីរាជការ ២១៨

១០-២-១៩៩៥ -អនុក្រឹត្យលេខ ១៦ អនក្រ ស្តីពីការប្រគល់ឋានន្តរសក្តិនាយទាហាន ២១៩

១៥-២-១៩៩៥ -អនុក្រឹត្យលេខ ១៧ អនក្រ ស្តីពីការតែងតាំងមន្ត្រីរាជការ ២២០

២.សេចក្តីសំរេច

១៣-២-១៩៩៥ -សេចក្តីសំរេចលេខ ១៨ សសរ ស្តីពីការបង្កើតទីស្នាក់ការគយរដ្ឋាករថ្មី
នៅតាមបណ្តាខេត្តមួយចំនួន ២២១

៣.សារាចរ

៩-២-១៩៩៥ -សារាចរលេខ ០២ សរ ស្តីពីការប្រលងប្រណាំងកែលំអសោភ័ណភាព
ខេត្ត-ក្រុង ទូទាំងប្រទេស.. ២២២

II-ការងារបណ្តាក្រសួង

១.ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

១៤-២-១៩៩៥ -ប្រកាសលេខ ០០៨ សហវ.ធ ស្តីពីការផ្ទេរឥណទាន ២២៦

២.ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ប្រកាស

១១-២-១៩៩៥ -ប្រកាសលេខ ០៤១ ពណ ពកប.ប្រក ស្តីពីការលុបចោលអាជ្ញាប័ណ្ណនាំចេញ
ឈើគ្រប់ប្រភេទរបស់បណ្តាក្រុមហ៊ុនមួយចំនួន.................................. ២២៨

៣.ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

១៤-២-១៩៩៥ -ប្រកាសលេខ ១២៥ ផក.ប្រក អនុញ្ញាតអោយលោក សៅ សុផាត ជនជាតិខ្មែរ
បើកដំណើរការរោងជាងផលិតទ្វារ បង្អួចដែក ២២៩

១៤-២-១៩៩៥ -ប្រកាសលេខ ១២៦ ផក.ប្រក អនុញ្ញាតអោយលោក ខ្លូតយ៉ាន ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ ២៣០

១៤-២-១៩៩៥ -ប្រកាសលេខ ១២៧ ផក.ប្រក អនុញ្ញាតអោយលោក នៅ សំបូរ ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ ២៣០

១៤-២-១៩៩៥ -ប្រកាសលេខ ១២៨ ផក.ប្រក អនុញ្ញាតអោយលោក សួន ទូច ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ ២៣១

១៤-២-១៩៩៥ -ប្រកាសលេខ ១២៩ ផក.ប្រក អនុញ្ញាតអោយលោក ទ្រី ផារៀន ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៥០ សេះ............................ ២៣១

១៤-២-១៩៩៥ -ប្រកាសលេខ ១៣០ ផក.ប្រក អនុញ្ញាតអោយលោក សុខ ជាវ ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ............................ ២៣២

១៤-២-១៩៩៥ -ប្រកាសលេខ ១៣១ ផក.ប្រក អនុញ្ញាតអោយលោក ឆៃ ឃី ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ ២៣២

១៤-២-១៩៩៥ -ប្រកាសលេខ ១៣២ ផក.ប្រក អនុញ្ញាតអោយលោក ថៃ សេង ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ ២៣៣

១៤-២-១៩៩៥ -ប្រកាសលេខ ១៣៣ ផក.ប្រក អនុញ្ញាតអោយលោក ម៉ែន សាធុន ជនជាតិខ្មែរ
បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ............................ ២៣៣

១៤-២-១៩៩៥ -ប្រកាសលេខ ១៣៤ ផក.ប្រក អនុញ្ញាតអោយលោក នាង ហ៊ិល ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២ សេះ ២៣៤

១៤-២-១៩៩៥ -ប្រកាសលេខ ១៣៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ជា ផាត ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ ២៣៤

១៤-២-១៩៩៥ -ប្រកាសលេខ ១៣៦ ផក.ប្រក អនុញ្ញាតអោយលោក កែវ គីង ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ ២៣៤

១៤-២-១៩៩៥ -ប្រកាសលេខ ១៣៧ ផក.ប្រក អនុញ្ញាតអោយលោក ផៃ សារ៉ាន ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ ២៣៥

១៤-២-១៩៩៥ -ប្រកាសលេខ ១៣៨ ផក.ប្រក អនុញ្ញាតអោយលោក សៀង វ៉េង ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២០ សេះ ២៣៦

១៤-២-១៩៩៥ -ប្រកាសលេខ ១៣៩ ផក.ប្រក អនុញ្ញាតអោយលោក ជុំ ចាន់ថន ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ២៣៦

១៤-២-១៩៩៥ -ប្រកាសលេខ ១៤០ ផក.ប្រក អនុញ្ញាតអោយលោក អៀ លី ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ ២៣៧

១៤-២-១៩៩៥ -ប្រកាសលេខ ១៤១ ផក.ប្រក អនុញ្ញាតអោយលោក សោម ស៊ីវ ជនជាតិខ្មែរ
បើកដំណើរការ ឧស្សាហកម្មតូចផលិតគ្រឿងបន្លាស់កៅស៊ូសំរាប់ម៉ូតូ រថយន្ត ២៣៧

១៤-២-១៩៩៥ -ប្រកាសលេខ ១៤២ ផក.ប្រក អនុញ្ញាតអោយលោក ជាក់ ទ្រី ជនជាតិខ្មែរ
បើកដំណើរការឡផលិតនំប៉័ង ២៣៨

១៤-២-១៩៩៥ -ប្រកាសលេខ ១៤៣ ផក.ប្រក អនុញ្ញាតអោយលោក គួ សុខខេត ជនជាតិខ្មែរ
ជាម្ចាស់រោងជាង ជួសជុលរថយន្ត ផ្ទេរភារកិច្ចគ្រប់គ្រងជូនអ្នកស្រី គីម សាអ៊ីម
សុវណ្ណារិត ២៣៨

១៤-២-១៩៩៥ -ប្រកាសលេខ ១៤៤ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី គីម អេង ជនជាតិខ្មែរ
បន្តដំណើរការសិប្បកម្មផលិតសាច់ដូយទាយីហោ " លុកធួក " ២៣៨

១៤-២-១៩៩៥ -ប្រកាសលេខ ១៤៥ ផក.ប្រក អនុញ្ញាតអោយលោក ចិន ស្រេង ជនជាតិខ្មែរ
បន្តដំណើរការសិប្បកម្មផលិតសរសៃគុយទាវយីហោ " រោង ហេង "........ ២៣៩

១៤-២-១៩៩៥ -ប្រកាសលេខ ១៤៦ ផក.ប្រក អនុញ្ញាតអោយលោក ចុង ខាវ ជនជាតិខ្មែរ
បើកដំណើរការឧស្សាហកម្មតូច ផលិតទឹកកកដើម ២៣៩

១៤-២-១៩៩៥ -ប្រកាសលេខ ១៤៧ ផក.ប្រក អនុញ្ញាតលោក ឡាយ ហ៊ិតឹម ជនជាតិខ្មែរ បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធ " បូកគោ " សញ្ញារូបភ្នំបូកគោ និងទឹកបរិសុទ្ធ " ហាវ៉ៃ " សញ្ញារូបកង៥ .... ២៤០

១៤-២-១៩៩៥ -ប្រកាសលេខ ១៤៨ ផក.ប្រក អនុញ្ញាតអោយលោក មួង ចន្ថា ជនជាតិខ្មែរ បើកដំណើរការរោង ជាងក្រឡឹងដែក ២៤០

១៤-២-១៩៩៥ -ប្រកាសលេខ ១៤៩ ផក.ប្រក អនុញ្ញាតអោយលោក ពាង ស្រេង ជនជាតិខ្មែរ បើកដំណើរការរោងជាងក្រឡឹងកែច្នៃគ្រឿងបន្លាស់ ២៤១

៤.ធីស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១០-២-១៩៩៥ -ប្រកាសលេខ ០២២/៩៥ ពម.ប្រក ស្ដីពីការទទួលស្គាល់លោក ស៊ុម គីមសេង មន្ត្រីរាជការរបស់មន្ទីរពត៌មានខេត្ត កំពង់ស្ពឺ ២៤១

១០-២-១៩៩៥ - ប្រកាសលេខ ០៣៨-៩៥ ពម. ២៤២

១៥-២-១៩៩៥ -ប្រកាសលេខ ៥៧/៩៥ ពម ស្ដីពីការសំរេចផ្អាកសារពត៌មាន " ឧត្តមគតិខ្មែរ " មិនអោយចេញផ្សាយរហូតដល់ច្បាប់សារពត៌មានថ្មីត្រូវបានអនុម័តដោយសភា ២៤៣

៥.ធីស្ដីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

ប្រកាស

១១-២-១៩៩៥ - ប្រកាសលេខ ១៩២ កទច ស្ដីពីការតែងតាំងបណ្ដោះអាសន្នចំពោះមន្ត្រីរាជការ និងក្របខ័ណ្ឌមន្ទីរទេសចរណ៍ខេត្តកំពង់ចាម ២៤៤

៦.ធីស្ដីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

១១-២-១៩៩៥ -ប្រកាសលេខ ០៣៨ ប.ទ ស្ដីពីការប្រើប្រាស់ថ្លៃសេវាប្រៃសណីយ៍ និង ទូរគមនាគមន៍ក្នុងប្រទេស និង អន្តរជាតិ ២៤៥

៧.ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

១៣_២_១៩៩៥ -ប្រកាសលេខ ៣២/៩៥ កធស.ប្រក ស្តីពីការលុបឈ្មោះបុគ្គលិក មន្ត្រីរាជការ ២៥៣

៨.រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

ប្រកាស

១១_២_១៩៩៥ -ប្រកាសលេខ ១៣០ ប្រក បស បល ស្តីពីការតែងតាំងមន្ត្រីរាជការ ២៥៥

១១_២_១៩៩៥ -ប្រកាសលេខ ១៣១ ប្រក បស បល ស្តីពីការផ្ទេរភារកិច្ចមន្ត្រី រាជការ ២៥៦

I- ទីស្តីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៥ អនក្រ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **លិម មិនចំនួ** ជាទីប្រឹក្សាឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង លោក **លិម មិនចំនួ** ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៦ អនក្រ
ស្តីពីការប្រគល់ឋានន្តរសក្តិ នាយទាហាន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត ក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា

-យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់ឋានន្តរសក្តិ ថ្នាក់ វរសេនីយ៍ឯក ដល់អស់លោក អតីតកងទ័ព កម្ពុជាប្រជាធិបតេយ្យ ចំនួន ០៤ រូប ដែលមានរាយនាមដូចខាងក្រោម ÷

១-លោក **អ៊ុក សំ**

២-លោក **ហួក ហ៊ុម**

៣-លោក **កុប ផន**

៤-លោក **ឡោ សុខ**

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី ក្រសួងពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៧ អនក្រ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារវប្បធម៌ វិចិត្រសិល្បៈរៀបចំទីកដីនគរោបនីយកម្ម និង សំណង់

សំរេច

មាត្រា ១ : តែងតាំងលោក **ស៊ុខ គង់** ជានាយកខុទ្ទកាល័យឯកឧត្តម **វង្ស ម៉ូលីវណ្ណ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកការងារវប្បធម៌ វិចិត្រសិល្បៈ រៀបចំទឹកដីនគរោបនីយកម្ម និង សំណង់ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងលោក **ស៊ុខ គង់** ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

២. សេចក្តីសំរេច

រាជធានីភ្នំពេញ ,ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ១៨ សសរ
ស្តីពីការបង្កើតទីស្នាក់ការគយ រដ្ឋាករថ្មី
នៅតាមបណ្តាខេត្តមួយចំនួន

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បង្កើតទីស្នាក់ការគយ-រដ្ឋាករថ្មី នៅតាមតំបន់ក្នុងបណ្តាខេត្តមួយចំនួន ដូចខាងក្រោម :

១-ទីស្នាក់ការគយ-រដ្ឋាករ សំរោង	ខេត្តស្វាយរៀង
២-ទីស្នាក់ការគយ-រដ្ឋាករ នាងកុក	ខេត្តកោះកុង
៣-ទីស្នាក់ការគយ-រដ្ឋាករ អណ្តូងចេញ	ខេត្តបាត់ដំបង
៤-ទីស្នាក់ការគយ-រដ្ឋាករ ស្ថានីយ៍រថភ្លើង	ខេត្តបាត់ដំបង
៥-ទីស្នាក់ការគយ-រដ្ឋាករ ភ្នំឬស្សី	ខេត្តពោធិសាត់
៦-ទីស្នាក់ការគយ-រដ្ឋាករ អូរស្មាច់	ខេត្តសៀមរាប
៧-ទីស្នាក់ការគយ-រដ្ឋាករ បឹងត្រកួន	ខេត្តបន្ទាយមានជ័យ
៨-ទីស្នាក់ការគយ-រដ្ឋាករ ជ័យឃ្លាំង	ខេត្តក្រចេះ
៩-ទីស្នាក់ការគយ-រដ្ឋាករ វាលី	ខេត្តក្រចេះ

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

៣. សារាចរ

រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

សារាចរលេខ ០២ សរ
ស្តីពីការប្រមូលប្រមូលសំរាមកែលំអ
សោភ័ណភាពខេត្ត-ក្រុង ទូទាំងប្រទេស

ក្នុងអំឡុងជាងពីរទសវត្សកន្លងមក ដែលព្រះរាជាណាចក្រកម្ពុជាយើង ត្រូវឆ្លងកាត់ព្យុះភ្លៀងនៃសង្គ្រាមមហាវិនាសកម្ម បានធ្វើអោយហេដ្ឋារចនាសម្ព័ន្ធសង្គមជាតិ ត្រូវបំផ្លិចបំផ្លាញផលប្រសគល់ ទាំងភោគទ្រព្យ និង ស្មារតីមនុស្ស ។ គេហដ្ឋានអាគារសាធារណៈ ផ្លូវថ្នល់ សួនកំសាន្តរមណីយដ្ឋាន ។ល។ ត្រូវរលត់រលាយស្ទើរទាំងស្រុង ដែលជំនួសមកវិញ នូវគំនរសំរាមស្អុយអសោចន៍ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិដ្ឋាន បង្កនូវរោគរាតត្បាតដល់ប្រជារាស្ត្រ ស្ទើរគ្រប់ច្រកល្ហកនៃទិប្រជុំជន ខេត្ត ក្រុង ទូទាំងប្រទេស ។

ប្រការនេះហើយដែលបណ្តាលអោយកិត្យានុភាពជាតិយើង ដែលធ្លាប់ល្បីរន្ទឺ ទូទាំងសកលលោកកាលពីសម័យសង្គមរាស្ត្រនិយម ដែលស្ថិតក្រោមព្រះរាជកិច្ចដឹកនាំ របស់អង្គសម្តេចឪជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃយើង ថាជាប្រទេសមួយប្រកបដោយ សោភ័ណភាពស្រស់បំព្រងពិសេសគឺរាជធានីភ្នំពេញ ដែលធ្លាប់តែមានសំរស់ដ៏ចិញ្ចែង ចិញ្ចាចនោះ ត្រូវអាប់ឱន និង ស្រុតចុះស្ទើរហោពុំគ្រ ។

បច្ចុប្បន្ននេះ បន្ទាប់ពីសន្តិភាពបានវិលមកលើទឹកដីយើងវិញហើយនោះ ទន្ទឹមនឹងការបដិសន្ធិឡើងនៃ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាមក យើងបានខិតខំពុះពារស្តារជាបណ្តើរៗ នូវកិត្យានុភាពជាតិយើងដែលក្នុងនោះ ខេត្ត-ក្រុងមួយចំនួន ដោយមានការជួយឧបត្ថម្ភ ពីសប្បុរសជនស្នេហាជាតិយើងផង បានដំណើរការរៀបចំកែលំអសោភ័ណភាពមូលដ្ឋានរបស់ខ្លួនទទួលបានលទ្ធផលគួរជាទីពេញចិត្ត ។

អាស្រ័យហេតុនេះ ដើម្បីលើកស្ទួយការកែលំអសោភ័ណភាពខេត្ត-ក្រុង អោយកាន់តែមានលក្ខណៈទូលំទូលាយ និងមានប្រសិទ្ធភាពទូទាំងប្រទេសអោយដូចសម័យសង្គមរាស្ត្រនិយម និងឈានទាន់បណ្តាអារ្យប្រទេសលើសកលលោកនោះ រាជរដ្ឋាភិបាលបានសំរេចដាក់ចេញនូវខ្លឹមសារប្រលងប្រណាំង ស្តីពីការកែលំអសោភ័ណភាព ខេត្ត-ក្រុង ដូចខាងក្រោមនេះ ÷

១-កែលំអសោភ័ណភាពខេត្ត-ក្រុង គឺត្រូវបំពេញអោយបាននូវការរៀបចំ សំអិតសំអាង កែលំអមូលដ្ឋានទីប្រជុំជន និង រៀបចំសណ្តាប់ធ្នាប់ រៀបចំការងារអនាម័យជាទូទៅ :

-កសាង កែលំអសួនកំសាន្តសាធារណៈ សួនកុមារ សួនឧទ្យានធម្មជាតិ ដាំដុះព្រៃឈើអោយល្អ ។

-មូលដ្ឋានខេត្ត-ក្រុងណា ដែលមានស្ទឹង ទន្លេ កោះ សមុទ្រ ត្រូវរៀបចំកែច្នៃធ្វើជាកន្លែងរមណីយដ្ឋានអោយ បានល្អ ដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ ។

-ត្រូវថែរក្សាការពារសំអាតប្រាសាទបុរាណ បូជនីយដ្ឋាន ដែលជាកេរ្តិ៍ដំណែលវប្បធម៌ជាតិអោយបានល្អ ។

-រៀបចំសណ្តាប់ធ្នាប់អនាម័យ បោសសំអាតឈូសឆាយចំបាត់សំរាម ភក់ជ្រាំ និង បណ្តាទីកន្លែងដែលមិនស្អាត ។

-រៀបចំសណ្តាប់ធ្នាប់ ផ្លូវថ្នល់ក្នុងមូលដ្ឋាន ដូចជាជួសជុលផ្លូវ រៀបចំកែលំអផ្លាកសញ្ញាចរាចរ ផ្លាកឈ្មោះ ផ្លូវ......... ។

-រៀបចំសណ្តាប់ធ្នាប់ ផ្ទះសំបែង ទីផ្សារសាធារណៈ អោយមានរបៀបរៀបរយ សោភ័ណភាព និងអនាម័យ ។

-រៀបចំប្រព័ន្ធឃោសនា ផ្សព្វផ្សាយអោយជ្រួតជ្រាបទូលំទូលាយ ដល់ប្រជារាស្ត្រគ្រប់មជ្ឈដ្ឋានអោយយល់ ច្បាស់ពីគុណប្រយោជន៍ជាតិ និង ចូលរួមថែរក្សាសោភ័ណភាព សណ្តាប់ធ្នាប់ អនាម័យ ព្រមទាំងសុជីវធម៌ក្នុងការរស់នៅ ។

-ខិតខំបំបាត់អោយអស់នូវ បណ្តាសំណង់អនាធិបតេយ្យ និង ជនអនាថា ដែលរស់នៅតាមទីសាធារណៈនានា ។

២-កែលំអសោភ័ណភាពខេត្ត-ក្រុង គឺសំដៅបំពេញអោយបានគោលបំណងទាំង ៣ ដូចខាងក្រោម :

-ធ្វើអោយទីប្រជុំជន ខេត្ត-ក្រុង មានសោភ័ណភាពស្រស់ល្អ មានសន្តិសុខសណ្តាប់ធ្នាប់ បរិសុទ្ធភាព និង ការ សំរាក កំសាន្តរបស់ប្រជារាស្ត្រ ទាក់ទាញបានភ្ញៀវទេសចរណ៍គ្រប់មជ្ឈដ្ឋាន ទាំងក្នុង និង ក្រៅប្រទេស ។

-ជាគំរូ ជំនួយដល់ការអភិវឌ្ឍន៍បណ្តាស្រុក មូលដ្ឋាន ភូមិឃុំ ជនបទជិតឆ្ងាយ ឈានដល់ភាពមានសណ្តាប់ ធ្នាប់អនាម័យ របៀបរៀបរយ ភូមិករណ៍ ផ្ទះសំបែងប្រជារាស្ត្រ ។

-បណ្តុះបានគំនិតយល់ដឹងរបស់ប្រជារាស្ត្រ អំពីសារៈសំខាន់ នៃកិច្ចការនេះ ហើយចូលរួមដោយភ្ញាក់រឮក ទាំងស្មារតី និង សំភារៈ ។

៣-ការអនុវត្តន៍ :

-ការប្រឡងប្រណាំងកែលំអសោភ័ណភាព ខេត្ត-ក្រុងនេះ ត្រូវចាប់ផ្តើមពីខែ មករា ឆ្នាំ ១៩៩៥ នេះតទៅ :

ចំពោះមុខ រាជរដ្ឋាភិបាល នឹងរៀបចំបង្កើតគណៈកម្មការជាតិមួយ សំរាប់ពិនិត្យវាយតំលៃ បូកសរុបការងារប្រលងប្រណាំងនេះ ទៅតាមដំណាក់កាលនីមួយៗ ដើម្បីធ្វើជាមូលដ្ឋានដល់ការ បូកសរុបលទ្ធផលដំណាច់ឆ្នាំ ។ គណៈកម្មការជាតិនេះ ត្រូវមានការចូលរួមពីគ្រប់ផ្នែកដែល

ពាក់ព័ន្ធដូចជា : ក្រសួងមហាផ្ទៃជាប្រធាន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងគ្រប់គ្រងបរិដ្ឋាន ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ ក្រសួងសុខាភិបាល ជាសមាជិក និង មានទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក អចិន្ត្រៃយ៍ ។

-គ្រប់ខេត្ត-ក្រុង ក៏ត្រូវបង្កើតគណៈកម្មការរបស់ខ្លួនមួយ ដើម្បីពិនិត្យ និងបំពេញបាន ល្អនូវការងារខាងលើនេះ ។

-រៀងរាល់ ៦ ខែ ម្តង ខេត្ត-ក្រុង ត្រូវរាយការណ៍ជាលាយលក្ខអក្សរ មកជូនគណៈកម្មការ ជាតិ ដែលមានទីស្នាក់ការអចិន្ត្រៃយ៍ នៅទីស្តីការគណៈរដ្ឋមន្ត្រី អំពីការងារដែលបានសំរេចហើយ គណៈកម្មការជាតិ ត្រូវធ្វើការបូកសរុបរាយការណ៍ ជូនរាជរដ្ឋាភិបាល ។

-រៀងរាល់ខែ ធ្នូ ចុងឆ្នាំ ត្រូវរៀបចំធ្វើសន្និបាតបូកសរុបលទ្ធផលទូទាំងប្រទេស ជ្រើសរើស ខេត្ត-ក្រុង ណាដែលសំរេចបានស្នាដៃល្អជាងគេ ដើម្បីលើកជាគំរូ និងផ្តល់គ្រឿងឥស្សរិយយស ជាកិច្ចលើកទឹកចិត្ត ។

៤.ប្រភពថវិកាសំរាប់បំរើអោយការងារប្រលងប្រណាំង :

ខេត្ត-ក្រុងនីមួយៗ ត្រូវខិតខំចលនាអោយសប្បុរសជននៅក្នុង និង ក្រៅប្រទេសអង្គការ ក្រៅរដ្ឋាភិបាល និង អង្គការ អន្តរជាតិនានា ជួយផ្តល់វិភាគទានជាថវិកា ជាសំភារៈតាមសមានចិត្ត ដើម្បីប្រមែប្រមូលបានជាទុនទុកសំរាប់បំរើ អោយការងារប្រលងប្រណាំងនេះ ។ ត្រូវជៀសវាង ដាច់ខាត ការស្នើយកថវិការដ្ឋដើម្បីប្រើប្រាស់សំរាប់បុណ្យហេតុប្រលងប្រណាំង ទោះបីជាបានមក ពីប្រភពចំណូលណាក៏ដោយ ។

សរុបមក ការងារកែលំអសោភ័ណភាពខេត្ត-ក្រុង គឺជាភារកិច្ចរួម និង ចាំបាច់ដែល គ្រប់ខេត្ត-ក្រុង ត្រូវពង្រីកកិច្ចសហការអោយបានទូលំទូលាយ ក្នុងគ្រប់មជ្ឈដ្ឋានប្រជារាស្ត្រ ក្នុងមូលដ្ឋានរបស់ខ្លួនដើម្បីរួមគ្នាប្រលងប្រណាំង កសាងស្នាដៃលើការងារនេះអោយទទួលបាន

លទ្ធផលជាវិជ្ជមាន និង ត្រូវត្រូចង់ជាប្រៀងជារាបទៅ ជាកិច្ចរួមចំណែកលើកកំពស់ មោទនភាពជាតិ យើងអោយបានរុងរឿង ដូចសម័យសង្គមរាស្ត្រនិយម ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខានិងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

***

II- ការងារបណ្តាក្រសួង

១. ទីស្តីការក្រសួងមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០០៨ សហវ.ឲ

ស្តីពីការផ្ទេរឥណទាន

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រមលេខ ០១ នស៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ១០ នស៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

-បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូកតាម ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួង តាមឥណទាន ចែងក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥

-បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥

-តាមសំណើរបស់ក្រសួងមហាផ្ទៃលេខ ១២៣៨ លស ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៤ ។

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិ នៅក្នុងរង្វង់ថវិកា របស់ក្រសួងមហាផ្ទៃសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការផ្ទេរឥណទានដូចបាន បញ្ជាក់ខាងក្រោមនេះ :

-ផ្នែកទី ២ : រដ្ឋបាលទូទៅ

ប្រភេទទី ១ : មធ្យោបាយសេវា

ជំពូក ១២ : ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល

ប្រការ ០១ : ប្រាក់ឧបត្ថម្ភ ខេត្ត-ក្រុង

ទឹកប្រាក់ត្រូវដក : ២៣៨.៧៥០.០០០ រៀលគត់

-ផ្ទេរទៅ :

ផ្នែកទី ៨ : ខេត្តនានា

ប្រភេទទី ១ : មធ្យោបាយសេវា

ជំពូក ១២ : ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការ អង្គការសាធារណៈរដ្ឋបាល

ប្រការ ០១ : ប្រាក់ឧបត្ថម្ភ ខេត្ត-ក្រុង

ទឹកប្រាក់ត្រូវបន្ថែម : ២៣៨.៧៥០.០០០ រៀលគត់

ប្រការ ២ : ឥណទានដែលបានផ្ទេរក្នុងប្រការខាងលើនេះ ត្រូវចំណាយដោយសាលាខេត្តមណ្ឌលគិរី សំរាប់ទិញស្បៀងឧបត្ថម្ភដល់ ប្រជារាស្ត្រ តាមស្នាមពីលិខិតលេខ ១៩៤១ សជណ.សរ ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៣ : ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តមអភិបាលខេត្តមណ្ឌលគីរី ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

***

២. ឯកសារនៃក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៤១ ពណ.ពកប.ប្រក

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល ។

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ចុះថ្ងៃទី ២៤-១០-១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល ។

-យោងអនុក្រឹត្យលេខ ១៣ អនក្រ ចុះថ្ងៃទី ១៩-០៦-១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធ ចាត់តាំងរបស់ក្រសួងពាណិជ្ជកម្ម

-ផ្អែកលើសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ២៨-០១-១៩៩៥ ស្តីពីនីតិវិធីនៃការនាំចេញឈើគ្រប់ប្រភេទ របស់ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

សំរេច

ប្រការ ១ : ក្រសួងពាណិជ្ជកម្មសូមប្រកាសលុបចោល នូវអាជ្ញាប័ណ្ណនាំចេញឈើគ្រប់ប្រភេទ របស់បណ្តាក្រុមហ៊ុនមួយចំនួនដូចខាងក្រោមនេះ :

-អាជ្ញាប័ណ្ណនាំចេញលេខ ០០៨ ពកប.ន ចុះថ្ងៃទី ១៣-០១-១៩៩៥ របស់ក្រុមហ៊ុនស៊ីនិម៉ិច

-អាជ្ញាប័ណ្ណនាំចេញលេខ ០០៩ ពកប.ន ចុះថ្ងៃទី ១៣-០១-១៩៩៥ របស់ក្រុមហ៊ុនស៊ីនីម៉ិច

-អាជ្ញាប័ណ្ណនាំចេញលេខ ០១០ ពកប.ន ចុះថ្ងៃទី ១៣-០១-១៩៩៥ របស់ក្រុមហ៊ុនស៊ីនីម៉ិច

-អាជ្ញាប័ណ្ណនាំចេញលេខ ០១៦ ពកប.ន ចុះថ្ងៃទី ១៦-០១-១៩៩៥ របស់ក្រុមហ៊ុនស៊ីនហ្វាតកូ

-អាជ្ញាប័ណ្ណនាំចេញលេខ ០១៧ ពកប.ន ចុះថ្ងៃទី ១៦-០១-១៩៩៥ របស់ក្រុមហ៊ុនស៊ីនហ្វាតកូ

-អាជ្ញាប័ណ្ណនាំចេញលេខ ០១៨ ពកប.ន ចុះថ្ងៃទី ១៦-០១-១៩៩៥ របស់ក្រុមហ៊ុនស៊ីនហ្វាតកូ

-អាជ្ញាប័ណ្ណនាំចេញលេខ ០១៩ ពកប.ន ចុះថ្ងៃទី ១៦-០១-១៩៩៥ របស់ក្រុមហ៊ុនស៊ីនហ្វាតកូ

-អាជ្ញាប័ណ្ណនាំចេញលេខ ០២១ ពកប.ន ចុះថ្ងៃទី ១៦-០១-១៩៩៥ របស់ក្រុមហ៊ុនកាឌីម៉ិច

-អាជ្ញាប័ណ្ណនាំចេញលេខ ០២៣ ពកប.ន ចុះថ្ងៃទី ១៦-០១-១៩៩៥ របស់ក្រុមហ៊ុនឃីតម៉ិច

-អាជ្ញាប័ណ្ណនាំចេញលេខ ០២៤ ពកប.ន ចុះថ្ងៃទី ១៦-០១-១៩៩៥ របស់ក្រុមហ៊ុន ឃីតម៉ិច

ប្រការ ២ : នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស សាម៉ីក្រុមហ៊ុន ស៊ីនីម៉ិច ,ស៊ីនហ្វាតកូ , កាឌីម៉ិច , ឃីតម៉ិច ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា និង ត្រា

ចម ប្រសិទ្ធ

***

៣-ផ្នែកការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ១២៥ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ :-អនុញ្ញាតអោយលោក សៅ សុផាត ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៩៤២៤៨ ភ.៣ ចុះថ្ងៃទី ១៩-១១-៨០ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦២ ផ្លូវលេខ ៤៥០ សង្កាត់ ទួលទំពូងទី ១ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ បើកដំណើរការ រោងជាងផលិតទ្វារ បង្អួចដែក នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១២៦ ផក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ : -អនុញ្ញាតអោយលោក ខួត យ៉ាន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៦៨៥១៥ ក.ណ ចុះថ្ងៃទី ១៧-៦-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ អន្លង់ស្លែង ឃុំ សំបួរមាស ស្រុក មុខកំពូល ខេត្ត កណ្តាល បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : លោក ខួត យ៉ាន បន្តផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករ លេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១២៧ ផក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ : -អនុញ្ញាតអោយលោក នៅ សំបួរ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៦៥០៣ ក.ណ ចុះថ្ងៃទី ២២-៥-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ជ្រៃមួយរយ ឃុំ សំបួរមាស ស្រុក មុខកំពូល ខេត្ត កណ្តាល បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ២ : លោក នៅ សំបួរ បន្តដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករ លេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១២៨ ផក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក សួន ទូច ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៦២៥៣៣ ភ.ព ចុះថ្ងៃទី ២៧_៧_៩០ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី១៧ សង្កាត់ អូរឫស្សីទី ៤ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំង ភូមិ ព្រហ៊ែក ឃុំ ស្វាយ ស្រុក បាទី ខេត្ត តាកែវ ។

ប្រការ ២ : លោក សួន ទូច ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផល អង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១២៩ ផក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ រោងម៉ាស៊ីនកិនស្រូវ ដែលមានលោក ទ្រី ផារឿន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ១០៦៨៨១ ប.ប ចុះថ្ងៃទី ០៦_៦_៨៨ ជាប្រធានអាស័យដ្ឋានបច្ចុប្បន្ន ភូមិ កូនក្អែក១ ឃុំ របស់មង្គល ស្រុក មោងឫស្សី ខេត្ត បាត់ដំបង បើកដំណើរការផលិតកម្ម ដោយប្រើ ម៉ាស៊ីន កំលាំង ៥០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : លោក ទ្រី ផារឿន ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករ លេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១៣០ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក សុខ ចាវ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៦៧៧៥ ក.ឆ ចុះថ្ងៃទី ០២-៣-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ២ ភូមិស្វាយជ្រុំថ្មី ឃុំ ស្វាយជ្រុំ ស្រុក រលាប្អៀរ ខេត្ត កំពង់ឆ្នាំង បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក សុខ ចាវ ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផល អង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១៣១ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក ផៃ ឃី ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៨១៣៤ សរ. ចុះថ្ងៃទី ១៨-០១-៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្លូវជាតិលេខ ៦ ក្រុមទី ១ ភូមិ កំពង់ក្តី ១ ឃុំ កំពង់ក្តី ស្រុក ជីក្រែង ខេត្ត សៀមរាប បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក ផៃ ឃី ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករ លេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១៣២ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក ថៃ សេង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១២១៣៧ ក.៣ ចុះថ្ងៃទី ២២-០៦-៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៧៦ ផ្លូវលេខ ៩៥ ក្រុមទី ៩ សង្កាត់បឹងត្របែក ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១៨ សេះ នៅក្នុងទីតាំង ភូមិ ព្រែកជ្រៃ ឃុំ ស្ពានថ្ម ស្រុក កណ្តាលស្ទឹង ខេត្ត កណ្តាល ។

ប្រការ ២ : លោក ថៃ សេង ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវ ទិន្នផលអង្ករ លេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១៣៣ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ រោងម៉ាស៊ីនកិនស្រូវដែលមានលោក ម៉ែន សាផុន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ១៤៨៣៧០ ស្វ.រ ចុះថ្ងៃទី ១៤-៣-៩០ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ភូមិ តាបីប ឃុំ បាវិត ស្រុក ចន្ទ្រា ខេត្ត ស្វាយរៀង បើក ដំណើរការ ផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ៩០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក ម៉ែន សាផុន ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវ ទិន្នផលអង្ករ លេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១៣៤ ផក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក នាង ហ៊ិល ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦៣៦៤៥ ស្វ.រ ចុះថ្ងៃទី ២៩-៤-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៧ ភូមិ ត្រោក ឃុំ តាសួស ស្រុក ស្វាយរៀង ខេត្ត ស្វាយរៀង បើកដំណើរការ រោង ម៉ាស៊ីនកិនស្រូវ កំលាំង ១២ សេះនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក នាង ហ៊ិល ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១៣៥ ផក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ អ្នកស្រី ជា ផាត ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣៦៨៩៦ ត.ក ចុះថ្ងៃទី ០១-០១-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ស្មោខ្ញី ឃុំ ត្រពាំងសាប ស្រុក បាទី ខេត្ត តាកែវ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៦ សេះ នៅក្នុងទីតាំង ភូមិ ត្រពាំងលាន ឃុំ ចំបក់ ស្រុក បាទី ខេត្ត តាកែវ ។

ប្រការ ២ : អ្នកស្រី ជា ផាត ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ១៣៦ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក កែវ គីង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៣៤៥២១ ស្ន.រ ចុះថ្ងៃទី ២៤-០១-៩១ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៨ ភូមិ គោកល្វៀង ឃុំ ព្រៃអង្គុញ ស្រុក ចន្ទ្រា ខេត្ត ស្វាយរៀង បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក កែវ គីង ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវ ទិន្នផលអង្ករ លេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

